ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តប៉ៃលិន

សំណុំរឿងរដ្ឋប្បវេណី
លេខ ០៧
ចុះថ្ងៃទី២១-០១-២០២០
សាលក្រមរដ្ឋប្បវេណី
លេខ៣៧..."យ" ចុះថ្ងៃទី
០៨ ខែ តុលា ឆ្នាំ២០២០

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តប៉ៃលិន

បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ជាសាធារណៈលើសំណុំរដ្ឋប្បវេណីលេខ ០៧ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២០ នាថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០២០ និងប្រកាសសាល ក្រមនៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ២០២០ នៅសាលាដំបូងខេត្តប៉ៃលិន ដោយមានសមាសភាព ដូចខាងក្រោម៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តប៉ៃលិន

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តប៉ៃលិន

រវាងដើមចោទឈ្មោះ [redacted] ស្ងលីន ភេទស្រី អាយុ៣៨ឆ្នាំ ជាតិខ្មែរ មានអាស័យដ្ឋាន[redacted]។

ដោយមានលោក [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] ស្ងលីន មានអាសយដ្ឋានបច្ចុប្បន្នតាំងនៅ[redacted]។

និងចុងចម្លើយឈ្មោះ [redacted] កាណារិន ភេទស្រី អាយុ៥៨ឆ្នាំ ជាតិខ្មែរ និងប្តីឈ្មោះ [redacted] គីមសេង មានទីលំនៅបច្ចុប្បន្ន[redacted]។

### អង្គហេតុ និងចំណុចវិវាទ

#### ១-ខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឲ្យតុលាការចេញ

១-ទាមទារអោយចុងចម្លើយសងប្រាក់ចំនួន៧៥៨,០០០(ប្រាំពីរសែនប្រាំម៉ឺនបួនពាន់)បាត និងលុយខ្មែរចំនួន២៧,៨០០,០០០(ម្ភៃប្រាំពីរលានប៉ែតសិបម៉ឺន) រៀល ។

២-សុំទាមទារសំណងជម្ងឺចិត្ត និងថ្លៃខាតបង់ពេលវេលាចំនួន១០,០០០(មួយម៉ឺនដុល្លារអាមេរិក) ។

៣-សុំអនុវត្តគ្រង់ចំណុច ១ ខាងលើ ។



Scanned with CamScanner

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**២-ការពន្យល់ត្រួសៗអំពីរឿងក្តី**

កាលពីថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៣ ភាគីចុងចម្លើយឈ្មោះ [redacted] កាណារិន និងប្តីឈ្មោះ [redacted] គឹមសេង បានមកខ្ចីលុយឈ្មោះ [redacted] សូលីនចំនួន៣០.០០០(បីម៉ឺន)បាត ដោយគិតការប្រាក់០៤% ក្នុងមួយខែ។ ក្រោយមកទៀតភាគីចុងចម្លើយបានមកខ្ចីប្រាក់ដើមចោទជាច្រើនលើសច្រើនសារទៀត ហើយភាគីចុងចម្លើយក៏បានសងការប្រាក់ និងប្រាក់ដើមមកដើមចោទជាបន្តបន្ទាប់ផងដែរ បន្ទាប់មកភាគីដើមចោទ និងចុងចម្លើយ បានទូទាត់ប្រាក់ដែលនៅសល់ចំនួន៦០០.០០០(ប្រាំមួយសែន) បាតទៀត ដែលភាគីចុងចម្លើយមិនទាន់សងគ្រប់ចំនួន និងការប្រាក់៣%ក្នុងមួយខែផងដែរ។ លុះដល់ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៥ ចុងចម្លើយបានទូទាត់ប្រាក់ជាមួយនិងដើមចោទសាជាថ្មី ដោយគិត ទាំងការប្រាក់ និងប្រាក់ដើមសរុបចំនួន៨០៤.០០០(ប្រាំបីសែនបួនពាន់)បាត ហើយទាំងភាគីចុងចម្លើយ និងខាងដើមចោទយល់ទទួលចំនួនប្រាក់សរុបដូចខាងលើនេះ ក្រោយមកទៀតនៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១៦ ចុងចម្លើយបានយកការប្រាក់ចំនួន៥០,០០០(ប្រាំម៉ឺន)បាត មកអោយដើមចោទ ហើយ នៅសល់ប្រាក់ចំនួន ៧៥៤,០០០(ប្រាំពីរសែនប្រាំម៉ឺនបួនពាន់)បាត និងលុយខ្មែរចំនួន២៧,៨០០,០០០ (ម្ភៃប្រាំពីរលានប៉ែតសិបម៉ឺន)រៀល ដែលចុងចម្លើយមិនទាន់សងគ្រប់ចំនួនរហូតមកដល់ពេល បច្ចុប្បន្ន គឺភាគីចុងចម្លើយមិនបានសងការប្រាក់ និងប្រាក់ដើមមកដើមចោទឡើយ ដូច្នេះទើបដើមចោទបានសម្រេចដាក់ពាក្យបណ្តឹងមកសាលាដំបូងខេត្តប៉ៃលិន ដើម្បីទាមទារដូចក្នុងពាក្យបណ្តឹង របស់ ខ្លួនចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០២០ និងពាក្យសុំកែតម្រូវ និងបន្ថែមកម្មវត្ថុបណ្តឹងចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០២០ ។

**៣-ការអះអាងរបស់ភាគី**

ក-ដើមចោទឈ្មោះ [redacted] សូលីន ដែលមានលោក [redacted] ជាមេធាវីតំណាងដោយអណត្តិឲ្យដើមចោទបានថ្លែងការណ៍ថា៖ ខ្លួននៅតែរក្សាខ្លឹមសាដូចក្នុងពាក្យបណ្តឹងរបស់កូនក្តីខ្លួនចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០២០ នៅដដែល ដោយសុំទាមទារឲ្យចុងចម្លើយសងប្រាក់ដើមចំនួន៧៥៤,០០០(ប្រាំពីរសែនប្រាំម៉ឺនបួនពាន់) បាត និងការប្រាក់ចំនួន ២៧,៨០០,០០០(ម្ភៃប្រាំពីរលានប្រាំបីសែន) រៀល និងសុំទាមទារសំណងជម្ងឺចិត្ត និងថ្លៃខាតបង់ពេលវេលាចំនួន១០,០០០(មួយម៉ឺនដុល្លារអាមេរិក) សុំអនុវត្តគ្រង់ចំណុច ១ ខាងលើ ដោយផ្អែកលើកិច្ចសន្យាខ្ចីប្រាក់រវាងកូនក្តីខ្លួន និងចុងចម្លើយរួមមាន ទីមួយ កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៣ ទីពីរកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១៤ ទីបីកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៥ និងទីបួនកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៦ ។

ខ-ចុងចម្លើយឈ្មោះ [redacted] កាណារិន បានធ្វើសេចក្តីថ្លែងការណ៍ថា: ខ្លួនទទួលស្គាល់ពិតជាបានខ្ចីប្រាក់ពីដើមចោទពិតមែន ប៉ុន្តែខ្លួនមិនមានលទ្ធភាពសងប្រាក់ទាំងអស់ទៅដើមចោទនោះទេ ហើយ



Scanned with CamScanner

ខ្លួនមានទ្វាភាពសងចំនួន ១០,០០,០០០ (ដប់លាន)រៀល ក្នុង ខែ កញ្ញា ឆ្នាំ ២០២០ ទៅអោយដើមចោទ ហើយខ្លួនសុំយកឡានចេញទៅវិញដើម្បីរកប្រាក់ចំណូលថែមទៀត ដោយខ្លួនសុំសងជាប្រាក់ក្នុងមួយឆ្នាំចំនួន ១០,០០,០០០ (ដប់លាន) រៀល ទៅអោយដើមចោទ ។ ហើយចំពោះជម្ងឺចិត្តចំនួន១០០០០ (មួយម៉ឺនដុល្លារអាមេរិក) ខ្លួនសុំអោយដើមចោទលុបចោលចំពោះការទាមទារចំណុចនេះ ហើយខ្លួនសុំយកឡាន ដែលមានជាប់ដីកាសម្រេចរក្សាការពារចេញទៅវិញ ។

គ-ចុងចម្លើយឈ្មោះ [redacted] គឹមសេង បានធ្វើសេចក្តីថ្លែងការណ៍ថា: ចំពោះការខ្ចីប្រាក់ពីដើមចោទគឺខ្លួនមិនបានខ្ចីនោះទេ គឺខ្លួនគ្រាន់តែបានដឹងថាប្រពន្ធខ្លួនឈ្មោះ [redacted] ណារិន បានខ្ចី លុយពីឈ្មោះ [redacted] ស្វលីន ប្រាកដមែន ប៉ុន្តែខ្លួនមិនមានលទ្ធភាពសងប្រាក់ទាំងអស់ទៅដើមចោទនោះទេ ហើយខ្លួនមានទ្វាភាពសងចំនួន ១០,០០,០០០ (ដប់លាន)រៀល ក្នុង ខែ កញ្ញា ឆ្នាំ ២០២០ ទៅអោយដើមចោទ ហើយខ្លួនសុំយកឡានចេញទៅវិញដើម្បីរកប្រាក់ចំណូលថែមទៀត ដោយខ្លួនសុំសងជាប្រាក់ក្នុងមួយឆ្នាំចំនួន ១០,០០,០០០ (ដប់លាន) រៀល ទៅអោយដើមចោទ ។ ហើយចំពោះជម្ងឺចិត្តចំនួន ១០០០០ (មួយម៉ឺនដុល្លារអាមេរិក) ខ្លួនសុំអោយដើមចោទលុបចោលចំពោះការទាមទារចំណុចនេះ ហើយខ្លួនសុំយកឡាន ដែលមានជាប់ដីកាសម្រេចរក្សាការពារចេញទៅវិញ ។

**៤-ចំណុចខខាន ៖ គ្មាន**

សហចុងចម្លើយទទួលស្គាល់ប្រាក់ដែលជំពាក់ដើមចោទ៧៥៤,០០០(ប្រាំពីរសែនប្រាំម៉ឺនបួនពាន់) បាត និងលុយខ្មែរចំនួន២៧,៤០០,០០០ (ម្ភៃប្រាំពីរលានបួនសែនសិបម៉ឺន) រៀល តាមកិច្ចសន្យាដូចខាងក្រោម៖

-កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៣ រវាងដើមចោទឈ្មោះ [redacted] ស្វលីន និងសហចុងចម្លើយឈ្មោះ [redacted] ណារិន និងប្តីឈ្មោះ [redacted] គឹមសេង ។

-កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១៤ រវាងដើមចោទឈ្មោះ [redacted] ស្វលីន និងសហចុងចម្លើយឈ្មោះ [redacted] ណារិន និងប្តីឈ្មោះ [redacted] គឹមសេង ។

-កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៥ រវាងដើមចោទឈ្មោះ [redacted] ស្វលីន និងសហចុងចម្លើយឈ្មោះ [redacted] ណារិន និងប្តីឈ្មោះ [redacted] គឹមសេង ។

-កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៦ រវាងដើមចោទឈ្មោះ [redacted] ស្វលីន និងសហចុងចម្លើយឈ្មោះ [redacted] ណារិន និងប្តីឈ្មោះ [redacted] គឹមសេង។

**សំអាងហេតុ**

១-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ភាគី នៅក្នុងនីតិវិធីសម្រាប់ការទាញហេតុផល និងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាងជាឯសារឃើញថា: តាមពាក្យបណ្តឹងរបស់ដើមចោទចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០២០ និងពាក្យសុំបន្ថែមកម្មវត្ថុនៃបណ្តឹងរបស់មេធាវីតំណាងដោយអាណត្តិអោយដើមចោទចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០២០ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ដែលអាចអោយតុលាការលើកយកមកពិចារណាបាន ។



Scanned with CamScanner

២-តាមការអះអាងរបស់មេធាវីតំណាងដោយអាណត្តិអោយដើមចោទបានបញ្ជាក់ថា: កូនក្តីខ្លួននៅតែរក្សាការទាមទារដូចក្នុងពាក្យបណ្តឹងរបស់ខ្លួនចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០២០ និងពាក្យបន្ថែមកម្មវត្ថុបណ្តឹងចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០២០ នៅដដែល ដោយសំអាងថាសហចុងចម្លើយឈ្មោះ [redacted] ណារិន និងប្តីឈ្មោះ [redacted] គីមសេង បានជំពាក់ប្រាក់កូនក្តីខ្លួនទាំងប្រាក់ដើម និងការប្រាក់ចំនួន៧៥៤,០០០(ប្រាំពីរសែនប្រាំម៉ឺនបួនពាន់)បាត និងលុយខ្មែរចំនួន២៧,៨០០,០០០(ម្ភៃប្រាំពីរលានប៉ែតសិបម៉ឺន) រៀល ដោយផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៣ ,កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១៤ , កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៥ ,កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៦ រវាងដើមចោទឈ្មោះ [redacted] សូលីន និង សហចុងចម្លើយឈ្មោះ [redacted] ណារិន និងប្តីឈ្មោះ [redacted] គីមសេង និងឲ្យសុំតុលាការអនុវត្តបណ្តោះអាសន្នគ្រប់ចំណុច ១ នៃកម្មវត្ថុខាងលើ ។

៣-សហចុងចម្លើយឈ្មោះ [redacted] កាណារិន និងប្តីឈ្មោះ [redacted] គីមសេង បានបញ្ជាក់ថា៖ខ្លួនទទួលស្គាល់ថាពិតជាបានជំពាក់លីខ្ចីប្រាក់ពីដើមចោទសរុបទាំងប្រាក់ដើមនិងការប្រាក់ចំនួន៧៥៤,០០០ (ប្រាំពីរសែនប្រាំម៉ឺនបួនពាន់)បាត និងលុយខ្មែរចំនួន ២៧,៨០០,០០០ (ម្ភៃប្រាំពីរលានប៉ែតសិបម៉ឺន) រៀល ពិតមែន ប៉ុន្តែខ្លួន និងប្រពន្ធមិនមានលទ្ធភាពសងប្រាក់ទាំងអស់ទៅដើមចោទនោះទេ ហើយខ្លួនមានទ្ធភាពសងចំនួន ១០០,០០០០ (ដប់លាន)រៀល ក្នុង ខែកញ្ញា ឆ្នាំ២០២០ ទៅអោយដើមចោទ ហើយខ្លួនសុំយកឡានចេញទៅវិញដើម្បីរកប្រាក់ចំណូលថែមទៀត ដោយខ្លួនសុំសងជាប្រាក់ក្នុងមួយឆ្នាំចំនួន ១០០,០០០០ (ដប់លាន) រៀល ទៅអោយដើមចោទ ។ ហើយចំពោះជម្ងឺចំនួន ១០០០០ (មួយម៉ឺនដុល្លាអាមេរិក) ខ្លួន និងប្រពន្ធសុំអោយដើមចោទលុបចោលចំពោះការទាមទារចំណុចនេះ ហើយសុំយកឡានដែលជាប់ដីកាសម្រេចរក្សាការពាររបស់សាលាដំបូងយកទៅប្រើប្រាស់វិញ ។

៤-តាមអះអាងតបរបស់មេធាវីតំណាងដោយអាណត្តិអោយដើមចោទបានបញ្ជាក់ថា: កូនក្តីខ្លួនមិនឯកភាពតាមស្នើសុំរបស់សហចុងចម្លើយនោះទេ ដោយសហចុងចម្លើយមិនបានអនុវត្តតាមកិច្ចរបស់ពួកគេធ្វើឲ្យកូនក្តីខ្លួនខាងបង់ផលប្រយោជយ៍យ៉ាងធ្ងន់ធ្ងរ ។

៥-តាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៣ ,កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១៤ , កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៥ ,កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៦ រវាងដើមចោទឈ្មោះ [redacted] សូលីន និង សហចុងចម្លើយឈ្មោះ [redacted] ណារិន និងប្តីឈ្មោះ [redacted] គីមសេង គូភាគីពិតជាបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ជាមួយគ្នាពិតប្រាកដមែន ហើយការបង្កើតកិច្ចសន្យានេះមានលក្ខណៈត្រឹមត្រូវតាម ៥៧៨ និងមាត្រា ៥៧៩ នៃក្រមរដ្ឋប្បវេណី ដែលអាចអោយតុលាការលើកយកការទាមទាររបស់ដើមចោទមកចាត់ការតាមនីតិវិធីបាន ។

៦-ចំពោះការប្រាក់ ភាគីដើមចោទប្តឹងទាមទារឲ្យភាគីសហចុងចម្លើយសងការប្រាក់ចំនួន៤% ក្នុងមួយខែលើប្រាក់ដើមចំនួន ៦០០,០០០(ប្រាំមួយសែនបាត) ដោយសរុបទាំងប្រាក់ដើមនិងការប្រាក់ចំនួន ៧៥៤,០០០ (ប្រាំពីរសែនប្រាំម៉ឺនបួនពាន់)បាត ហើយសហចុងចម្លើយក៏បានទទួលស្គាល់

នូវចំនួនទឹកប្រាក់ដែលបានទាមទារដែរ ប៉ុន្តែខ្លួនពុំមានលទ្ធភាពសងប្រាក់ទៅភាគីដើមចោទនោះឡើយ ។

៧-ចំពោះសំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលាដែលដើមចោទទាមទារចំនួន១០,០០០( មួយដុល្លាអាមេរិក) , តុលាការពិនិត្យឃើញថា ដោយសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីប្រាក់ ដែលជាហេតុធ្វើដើមចោទដាក់ពាក្យបណ្តឹងទាមទារប្រាក់តាមប្រព័ន្ធតុលាការនោះ ពិតជាធ្វើឲ្យដើមចោទខាតបង់ពេលវេលា និងសេវាកម្មផ្លូវច្បាប់ប្រាកដមែន ដោយការទាមទាររបស់ដើមចោទមានលក្ខណៈសមស្របតាមបញ្ញត្តិមាត្រា ៣៩៨ នៃក្រមរដ្ឋប្បវេណី ប៉ុន្តែការទាមទាររបស់ដើមចោទ មានលក្ខណៈច្រើនពេក ដូច្នេះគប្បីតុលាការលើកយកចំណុចនេះមកពិចារណា ។

៨-ការប្រកាសអោយអនុវត្តបណ្តោះអាសន្នត្រង់ចំណុច ១ ភាគីដើមចោទបានប្តឹងសុំឲ្យតុលាការអនុវត្តបណ្តោះអាសន្ន ដោយសំអាងថាសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួននោះឡើយ ហើយបានអូសបន្លាយពេលអស់ជាច្រើនខែទៀតផង ដែលធ្វើខាតប្រយោជន៍ដល់កូនក្តីរបស់ខ្លួនយ៉ាងធ្ងន់ធ្ងរ ហើយតុលាការក៏យល់ឃើញថាបើមិនមានវិធានការណ៍ទប់ស្កាត់នូវអំពើទុច្ចរិតរបស់ភាគីសហចុងចម្លើយនោះទេ ច្បាស់ជាសហចុងចម្លើយនៅតែមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនដដែល បណ្តាលឲ្យភាគីដើមចោទបាត់បង់ផលប្រយោជន៍របស់ខ្លួនកាន់ខ្លាំងឡើងៗ ដូច្នេះការសុំរបស់ភាគីដើមចោទ ដោយសុំតុលាការចេញសាលក្រមអនុវត្តបណ្តោះអាសន្នត្រង់ចំណុច ១ មានលក្ខណៈសមស្របតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងមានភាពចាំបាច់ដែលធ្វើឲ្យតុលាការចេញសាលក្រមប្រកាសអោយអនុវត្តបណ្តោះអាសន្នបានដោយយោងតាមមាត្រា១៩៦នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៩-ប្រាក់ប្រដាប់ក្តី៖ យោងតាមមាត្រា ៦៤ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី , គប្បីតុលាការសម្រេចបង្គាប់ឲ្យចុងចម្លើយជាទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

១០-រាល់ចំណុចដូចបានចង្អុលបង្ហាញខាងលើបានបញ្ជាក់ឲ្យឃើញថា អង្គហេតុដែលជាមូលដ្ឋាននៃការទាមទាររបស់ដើមចោទខាងលើនេះ ពិតជាមានអត្ថិភាពនៃសិទ្ធិលើបំណុលប្រាកដមែន ដូច្នេះតុលាការគប្បីលើកយកពិចារណា និងសម្រេចតាមការទាមទាររបស់ដើមចោទតាមមាត្រា ៥៩១, មាត្រា ៣៩៨,មាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណី និងមាត្រា ១៩៦ ,មាត្រា ៦៤ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សម្រេចសេចក្តីបញ្ចប់

១-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] ណារិន និងប្តីឈ្មោះ [redacted] គឹមសេង បង់ប្រាក់បាតឲ្យភាគីដើមចោទឈ្មោះ [redacted] សូលីន ចំនួន ៧៥៤,០០០ (ប្រាំពីរសែនប្រាំម៉ឺនបួនពាន់)បាត និងប្រាក់ខ្មែរចំនួន ២៧,៨០០,០០០ (ម្ភៃប្រាំពីរលានប៉ែតសិបម៉ឺន) រៀល ។

២-បង្គាប់ឲ្យសហចុងចម្លើយ [redacted] ណារិន និងប្តីឈ្មោះ [redacted] គឹមសេង សងជម្ងឺចិត្ត និងថ្លៃខាតបង់ពេលវេលាដើមចោទឈ្មោះ [redacted] សូលីន ចំនួន ៤.០០០.០០០ (បួនលានរៀល)។



Scanned with CamScanner

៣-សាលក្រមនេះអាចអនុវត្តបណ្ដោះអាសន្នបានចំពោះចំណុច ១ នៃសេចក្ដីសម្រេចបញ្ចប់នេះ ។

៤-ភាគីចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី

-សាលក្រមនេះបានប្រកាសនៅសវនាការជាសាធារណៈនៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ២០២០ ក្នុងករណីដែលប្ដឹងឧទ្ធរណ៍ ត្រូវធ្វើក្នុងរយៈពេល ០១ (មួយ) ខែគិតចាប់ពីថ្ងៃដែលបានទទួលលិខិតសាលក្រមនេះ ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

................................................................................................................

**បានឃើញ**

ប៉ៃលិន,ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ២០២០

**ចៅក្រម**

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃ ព្រហស្បតិ៍ ៦ រោច ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ប៉ៃលិន,ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]